# ជំនួយសម្រាប់ឪពុកម្ដាយថ្មីដែលឈប់សម្រាកពីការងារ

មានជំនួយ ប្រសិនបើអ្នកជាឪពុកម្ដាយដែលចំណាយពេលឈប់ពីការងារដើម្បីថែទាំទារកទើបនឹងកើត ឬកូនដែលបានសុំយកមកចិញ្ចឹមពេលថ្មីៗនេះ។

## Parental Leave Pay

ការបង់ប្រាក់នេះជួយដល់ឪពុកម្ដាយទាំងឡាយណាដែលចំណាយពេលឈប់ពីការងារដើម្បីក្លាយជាជាអ្នកថែទាំកូនថ្មី។

ប្រសិនបើមានសិទ្ធិទទួលបាន អ្នកអាចទទួលបានការបង់ប្រាក់រហូតដល់ 18 សប្ដាហ៍ តាមអត្រា National Minimum Wage។ Parental Leave Pay គឺអាចកាត់ពន្ធបាន។ យើងក៏រាប់វាបញ្ចូលទៅក្នុងការធ្វើតេស្តប្រាក់ចំណូលផងដែរ ប្រសិនបើអ្នកទទួលបានការបង់ប្រាក់ជំនួយលើ ប្រាក់ចំណូលដូចជា Parenting Payment។ នេះមានន័យថា ប្រសិនបើអ្នកទទួលបានការបង់ប្រាក់ជំនួយលើប្រាក់ចំណូល Parental Leave Pay របស់អ្នក អាចកាត់បន្ថយ ឬបញ្ឈប់។

## អ្នកណាខ្លះដែលអាចទទួលបានវា?

អ្នកអាចទទួលបាន Parental Leave Pay ប្រសិនបើអ្នក៖

- ជាអ្នកថែទាំចម្បងនៃទារកដែលទើបនឹងកើត ឬកូនដែលបានសុំយកមកចិញ្ចឹមថ្មី។
- រកចំណូលបានតិចជាង $150,000 នៅក្នុងឆ្នាំហិរញ្ញវត្ថុឆ្នាំមុន
- បានធ្វើការ 10 ខែ នៃ 13 ខែ នៅមុនពេលកំណើត ឬការសុំកូនរបស់អ្នកយកមកចិញ្ចឹម
- បំពេញបានតាមបទបញ្ញត្តិក្នុងការស្នាក់នៅ។

ដើម្បីទទួលបានការបង់ប្រាក់ចំនួន 18 សប្ដាហ៍ពេញនៃ Parental Leave Pay អ្នកត្រូវតែស្ថិតនៅក្នុងការឈប់សម្រាក ឬមិនធ្វើការនៅក្នុងរយៈពេល Paid Parental Leave របស់អ្នក។

ប្រសិនបើអ្នកមិនអាចទទួលបាន Parental Leave Pay ទេ នោះអ្នកប្រហែលជាអាចទទួលបាន Newborn Upfront Payment និង Newborn Supplement។ អ្នកអាចទទួលបានវា ប្រសិនបើអ្នកកំពុងទទួលបាន Family Tax Benefit Part A។

## ពេលណាអ្នកអាចទទួលវាបាន

នៅពេលអ្នកទាមទារ នោះអ្នកនឹងជ្រើសរើសកាលបរិច្ឆេទចាប់ផ្ដើម។ កាលបរិច្ឆេទចាប់ផ្ដើមរបស់អ្នកមិនអាចនៅមុនកាលបរិច្ឆេទនៃកំណើត ឬការសុំកូនយកមកចិញ្ចឹមទេ។

អ្នកអាចកំណត់យកកាលបរិច្ឆេទនៃកំណើត ឬការសុំកូនយកមកចិញ្ចឹមថាជាកាលបរិច្ឆេទចាប់ផ្ដើមបាន។ ដើម្បីធ្វើដូចនេះ អ្នកត្រូវការធ្វើនូវចំណុចទាំងពីរនៅក្នុង 4 សប្ដាហ៍ដូចតទៅ ក្រោយកំណើត ឬការសុំកូនយកមកចិញ្ចឹម៖

- ដាក់បញ្ជូនការទាមទាររបស់អ្នក
- ផ្ដល់ភស្តុតាងនៃកំណើត ឬការសុំកូនយកមកចិញ្ចឹម។

ប្រសិនបើអ្នកមិនធ្វើដូច្នេះទេ កាលបរិច្ឆេទចាប់ផ្ដើមរបស់អ្នកអាចជាកាលបរិច្ឆេទដែលអ្នកបានដាក់បញ្ជូនការទាមទាររបស់អ្នកតែប៉ុណ្ណោះ។

អ្នកក៏អាចកំណត់យកកាលបរិច្ឆេទចាប់ផ្ដើមនៅពេលក្រោយផងដែរ។

ដើម្បីទទួលបានការបង់ប្រាក់ Parental Leave Pay ចំនួន 18 សប្ដាហ៍ពេញ អ្នកត្រូវការទាមទារ និងកំណត់យកកាលបរិច្ឆេទចាប់ផ្ដើម។ អ្នកត្រូវការធ្វើដូចនេះមិនឱ្យលើសពី៖

- 34 សប្តាហ៍ ក្រោយពីកំណើត ឬការសុំកូនយកមកចិញ្ចឹម ប្រសិនបើវានៅមុនថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2020
- 40 សប្តាហ៍ ក្រោយពីកំណើត ឬការសុំកូនយកមកចិញ្ចឹម ប្រសិនបើវានៅថ្ងៃទី ឬក្រោយថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2020

អ្នកនឹងទទួលបានការបង់ប្រាក់ដំបូងរបស់អ្នកក្រោយកាលបរិច្ឆេទចាប់ផ្តើមដែលបានកំណត់យករបស់អ្នក។

## របៀបដែលអ្នកនឹងទទួលបាន Parental Leave Pay

Parental Leave Pay ត្រូវបានបង់ឱ្យរហូតដល់ 18 សប្តាហ៍។ វាអាចបង់ក្នុងរយៈពេល 90 ថ្ងៃ។

ប្រសិនបើកំណើត ឬការសុំកូនយកមកចិញ្ចឹមនៃកូនរបស់អ្នកនៅមុនថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2020 នោះរយៈពេល Paid Parental Leave របស់អ្នកនឹងជាប្លុកបន្តតែមួយដងរហូតដល់ 18 សប្តាហ៍។

ប្រសិនបើកំណើត ឬការសុំកូនយកមកចិញ្ចឹមនៃកូនរបស់អ្នកនៅថ្ងៃទី ឬក្រោយថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2020 នោះ Parental Leave Pay របស់អ្នកនឹងរួមបញ្ចូលទាំង៖

- រយៈពេល Paid Parental Leave ជាបន្ត រហូតដល់ 12 សប្តាហ៍ ដែលមានរយៈពេលអាចបង់បាន 60 ថ្ងៃ
- 30 Flexible Paid Parental Leave ថ្ងៃ។

ប្រសិនបើកំណើត ឬការសុំកូនយកមកចិញ្ចឹមនៃកូនរបស់អ្នកនៅថ្ងៃទី ឬក្រោយថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2020 នោះអ្នកអាចប្រើប្រាស់ចំនួនថ្ងៃនៃ Flexible Paid Parental Leave របស់អ្នកតាមរបៀប ជាច្រើន។ អ្នកអាច៖

- ភ្ជាប់វាទៅនឹងរយៈពេលនៃ Paid Parental Leave របស់អ្នក
- ចូលប្រើប្រាស់វានៅពេលក្រោយ នៅពេលណាដែលសមស្របនឹងអ្នក
- ផ្តល់វាឱ្យទៅមនុស្សផ្សេងទៀតដូចជាដៃគូរបស់អ្នក ដើម្បីប្រើប្រាស់ចំនួនថ្ងៃដែលពួកគេមានក្នុងការថែទាំកូន។

អ្នកអាចទទួលបាន Flexible Paid Parental Leave លើចំនួនថ្ងៃដែលអ្នក៖

- កំពុងថែទាំកូនរបស់អ្នក
- កំពុងស្ថិតក្នុងការឈប់សម្រាកពីការងារ ឬមិនធ្វើការ
- បំពេញបានតាមបទបញ្ញត្តិក្នុងការស្នាក់នៅ។

និយោជករបស់អ្នក ឬយើងនឹងបង់ Parental Leave Pay របស់អ្នក អាស្រ័យលើកាលៈទេសៈរបស់អ្នក។

ប្រសិនបើនិយោជករបស់អ្នកបង់ឱ្យអ្នក នោះអ្នកនឹងទទួលបានការបង់ប្រាក់របស់អ្នកតាមវដ្តបង់ប្រាក់ធម្មតា របស់អ្នក។ យើងនឹងដំណើរការរឿងនេះជាមួយនិយោជករបស់អ្នក។

ប្រសិនបើអ្នកមិនទទួលបាន Parental Leave Pay របស់អ្នកពីនិយោជករបស់អ្នកទេ ឬប្រសិនបើអ្នកជាអ្នកធ្វើការ រកស៊ីខ្លួនឯង នោះយើងនឹងបង់ឱ្យអ្នកដោយផ្ទាល់ជារៀងរាល់ពីរសប្តាហ៍ម្តង។

យើងអាចបង់វានៅក្នុងរយៈពេល 104 សប្តាហ៍នៃកំណើត ឬការសុំយកមកចិញ្ចឹមនៃកូនរបស់អ្នក។ យើងនឹងបង់ចំនួនថ្ងៃណាមួយនៃ Flexible Paid Parental Leave ដែលអ្នកមិនបានភ្ជាប់ទៅរយៈពេលនៃ Paid Parental Leave របស់អ្នក។

## Dad and Partner Pay

Dad and Partner Pay គឺជាការបង់ប្រាក់សម្រាប់រយៈពេលរហូតដល់ 2 សប្តាហ៍។ វាជួយដល់ឪពុក ឬដៃគូទាំងឡាយដែលចំណាយពេលឈប់ពីការងារដើម្បីថែទាំកូនថ្មីរបស់ពួកគេ។

ប្រសិនបើអ្នកមានសិទ្ធិទទួលបាន អ្នកអាចទទួលបានការបង់ប្រាក់រហូតដល់ 2 សប្តាហ៍ តាមអត្រា National Minimum Wage។
យើងនឹងបង់ទៅឱ្យអ្នកដោយផ្ទាល់ចូលទៅក្នុងគណនីធនាគារដែលបានកំណត់យករបស់អ្នកនៅក្នុងការបង់ប្រាក់មួយ។ Dad and Partner Pay គឺអាចកាត់ពន្ធបាន។

អ្នកអាចទទួលបាន Dad and Partner Pay នៅពេលណាមួយក៏បាន នៅក្នុងពេល 52 សប្តាហ៍នៃកំណើត ឬការសុំយកមកចិញ្ចឹមនៃកូនរបស់អ្នក។

## អ្នកណាខ្លះដែលអាចទទួលបានវា?

អ្នកប្រហែលជាអាចទទួលបាន Dad and Partner Pay ប្រសិនបើអ្នកស្ថិតនៅក្នុងចំណុចណាមួយខាងក្រោម៖

- ជាឪពុកបង្កើតនៃកូននោះ
- ដៃគូរបស់ម្តាយដែលផ្តល់កំណើត
- ជាឪពុកម្តាយ ឬដៃគូចិញ្ចឹមនៃឪពុកម្តាយចិញ្ចឹម
- មនុស្សកំពុងថែទាំកូនដែលកើតមកតាមរយៈកិច្ចព្រមព្រៀងក្នុងការពរពោះជំនួស។

អ្នកក៏នឹងត្រូវបំពេញតាមលក្ខខណ្ឌមួយដូចតទៅ៖

- ផ្តល់ការថែទាំដល់ទារកទើបនឹងកើត ឬកូនដែលសុំយកមកចិញ្ចឹមថ្មី
- រកចំណូលបានតិចជាង $150,000 នៅក្នុងឆ្នាំហិរញ្ញវត្ថុឆ្នាំមុន
- នឹងមិនធ្វើការ ឬយកការឈប់សម្រាកពីការងារដោយមានបង់ប្រាក់នៅក្នុងអំឡុងនៃរយៈពេល Dad and Partner Pay របស់អ្នក
- ត្រូវបំពេញតាមការធ្វើតេស្តការងារ
- បំពេញបានតាមបទបញ្ញត្តិក្នុងការស្នាក់នៅ។

## ការធ្វើតេស្តការងារសម្រាប់ Parental Leave Pay និង Dad and Partner Pay

ដើម្បីទទួលបាន Parental Leave Pay ឬ Dad and Partner Pay អ្នកត្រូវបំពេញតាមការធ្វើតេស្តការងារ។
អ្នកត្រូវតែបានធ្វើការរយៈពេលយ៉ាងហោចណាស់ 330 ម៉ោង ប្រហែល 1 ថ្ងៃ ក្នុងមួយសប្តាហ៍។
អ្នកត្រូវបានធ្វើការក្នុងម៉ោងទាំងនេះនៅក្នុង 10 ខែ នៃ 13 ខែណាមួយ៖

- នៅមុនពេលកំណើត ឬការសុំកូនយកមកចិញ្ចឹមរបស់អ្នកសម្រាប់ Parental Leave Pay
- នៅមុនកាលបរិច្ឆេទនៃរយៈពេល Dad and Partner Pay របស់អ្នកចាប់ផ្តើម។

ប្រសិនបើកំណើតនៃកូនរបស់អ្នក ឬការសុំកូនយកមកចិញ្ចឹមរបស់អ្នកមុនថ្ងៃទី 1 ខែមករា ឆ្នាំ 2020 អ្នកមិនអាច មានគម្លាតច្រើនជាង 8 សប្តាហ៍រវាងថ្ងៃការងារនីមួយៗទេ។

ប្រសិនបើកំណើតនៃកូនរបស់អ្នក ឬការសុំកូនយកមកចិញ្ចឹមរបស់អ្នកនៅថ្ងៃទី ឬក្រោយថ្ងៃទី 1 ខែមករា ឆ្នាំ 2020 អ្នកមិនអាច មានគម្លាតច្រើនជាង 12 សប្តាហ៍រវាងថ្ងៃការងារនីមួយៗទេ។

ការលើកលែងមួយចំនួនអនុវត្តចំពោះកំណើតមិនគ្រប់ខែ និងការមានផ្ទៃពោះទាក់ទងនឹងជំងឺ និងភាពស្មុគស្មាញនៃជំងឺនានា។

សម្រាប់ Parental Leave Pay មានមាត្រាទាក់ទងនឹង Dangerous Jobs។ ករណីនេះ ប្រសិនបើកំណើតកូន ឬការសុំកូនយកមកចិញ្ចឹមរបស់អ្នកនៅថ្ងៃទី ឬក្រោយថ្ងៃទី 1 ខែមករា ឆ្នាំ 2020។ វានឹងអនុវត្ត

ប្រសិនបើអ្នកចាំបាច់ត្រូវឈប់ធ្វើការដោយតែមានហានិភ័យចំពោះការមានផ្ទៃពោះរបស់អ្នក។ អ្នកនឹងត្រូវការបំពេញទៅតាមការធ្វើតេស្តការងារ ដើម្បីទទួលបាន Parental Leave Pay។

## របៀបដើម្បីទាមទារ Parental Leave Pay និង Dad and Partner Pay

1. ទទួលបាន Customer Reference Number (CRN)

អ្នកនឹងត្រូវការបង្កើតអត្តសញ្ញាណរបស់អ្នក ដើម្បីទទួលបាន CRN។ ប្រសិនបើអ្នកមានវា ហើយអ្នកបានបញ្ជាក់អត្តសញ្ញាណរបស់អ្នករួចហើយ សូមប្រើប្រាស់វាដើម្បីតភ្ជាប់គណនី Centrelink នៅលើអ៊ីនធឺណិតរបស់អ្នក ទៅគណនី myGov របស់អ្នក។

2. ដាក់ការទាមទាររបស់អ្នកដោយប្រើគណនី Centrelink នៅលើអ៊ីនធឺណិតរបស់អ្នកតាមរយៈ myGov

អ្នកអាចធ្វើដូចនេះបានរហូតដល់ 3 ខែ នៅមុនពេលកាលបរិច្ឆេទដែលរំពឹងទុកនៃកំណើត ឬការសុំកូនយកមក ចិញ្ចឹមរបស់អ្នក។

3. ផ្តល់ភស្តុតាងនៃកំណើតកូន ឬការសុំកូនយកមកចិញ្ចឹមរបស់អ្នក

អ្នកនឹងត្រូវការដាក់បញ្ជូនភស្តុតាងនៃកំណើតកូន ឬការសុំកូនយកមកចិញ្ចឹមរបស់អ្នកនៅក្នុងរយៈពេល 4 សប្តាហ៍ នៃពួកគេ ដែលនឹងចូលមកក្នុងការថែទាំរបស់អ្នក។ ប្រសិនបើអ្នកមិនធ្វើដូចនេះទេ អ្នកមិនអាចត្រូវបានគេបង់ប្រាក់ឱ្យទេ គិតពីកាលបរិច្ឆេទនៃកំណើត ឬការសុំកូនយកមកចិញ្ចឹមរបស់ពួកគេ។

ក្រោយកំណើតកូនរបស់អ្នក អ្នកនឹងទទួលបានទម្រង់បែបបទ Newborn Child Declaration មួយពីមន្ទីរពេទ្យ ឬឆ្មបរបស់អ្នក។ អ្នកអាចបង្ហោះទម្រង់បែបបទនេះតាមអ៊ីនធឺណិតបាន។

អ្នកក៏នឹងត្រូវការចុះឈ្មោះកំណើតជាមួយ Births, Deaths and Marriages Registry នៅក្នុងរដ្ឋ ឬដែនដីរបស់អ្នក។

## សិទ្ធិទទួលបានការឈប់សម្រាកពីការងារនៅកន្លែងធ្វើការ

Parental Leave Pay និង Dad and Partner Pay នឹងមិនផ្លាស់ប្តូរសិទ្ធិទទួលបានការឈប់សម្រាកពីការងារនៅកន្លែង ធ្វើការរបស់អ្នកទេ។

ដើម្បីចាត់ចែងការឈប់សម្រាកពីការងារ អ្នកនឹងត្រូវការនិយាយជាមួយនិយោជករបស់អ្នក។ អ្នកគួរតែព្យាយាមធ្វើដូចនេះឱ្យបានយ៉ាងហោចណាស់ 10 សប្តាហ៍នៅមុនពេលអ្នកមានបំណងយកការឈប់សម្រាក ពីការងារ។

អ្នកអាចមានសិទ្ធិទទួលបានចំពោះការឈប់សម្រាកក្នុងនាមជាឪពុកម្តាយដោយគ្មានការបង់ប្រាក់។ នេះគឺប្រសិនបើអ្នកបានធ្វើការជាបន្តបន្ទាប់សម្រាប់និយោជករបស់អ្នកអស់រយៈពេល 12 ខែ ឬច្រើនជាងនេះ។

ដើម្បីស្វែងយល់បន្ថែមអំពីសិទ្ធិទទួលបានការឈប់សម្រាកពីការងារនៅកន្លែងធ្វើការរបស់អ្នកជាភាសាអង់គ្លេស៖

- ទៅកាន់ **fairwork.gov.au**
- ហៅទូរសព្ទទៅ Fair Work Ombudsman តាមលេខ **131 394**
- ទៅកាន់ **supportingworkingparents.humanrights.gov.au**

## សម្រាប់ព័ត៌មានបន្ថែម

- សូមហៅទូរសព្ទទៅខ្សែទូរសព្ទបង់ប្រាក់ជាប្រចាំរបស់អ្នក និងប្រាប់យើងឱ្យដឹងថា អ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់។ យើងនឹងចាត់ចែងឱ្យមានអ្នកបកប្រែផ្ទាល់មាត់ដោយឥតគិតថ្លៃ។ សម្រាប់បញ្ជីនៃលេខទូរសព្ទរបស់យើង សូមទៅ**កាន់ servicesaustralia.gov.au/phoneus**

- ហៅទូរសព្ទទៅលេខ **131 202** ដើម្បីនិយាយជាមួយយើងជាភាសារបស់អ្នកអំពីការបង់ប្រាក់ និងសេវាកម្ម Centrelink ។
- ហៅទូរសព្ទទៅ Translating and Interpreting Service (TIS National) តាមលេខ **131 450** ដើម្បីនិយាយជាមួយយើង ជាភាសារបស់អ្នកអំពីការបង់ប្រាក់ និងសេវាកម្មទាក់ទងនឹង Medicare និង Child Support ។
- ទៅកាន់ **servicesaustralia.gov.au/yourlanguage** ដែលអ្នកអាចអាន ស្ដាប់ ឬមើលព័ត៌មានជាភាសារបស់អ្នក។
- ទៅកាន់ **servicesaustralia.gov.au/parentalleavepay** ឬ **servicesaustralia.gov.au/dadandpartnerpay** សម្រាប់ព័ត៌មានបន្ថែមជាភាសាអង់គ្លេស។
- ទៅទស្សនាមជ្ឈមណ្ឌលសេវាកម្ម។

**ចំណាំ៖** ការហៅទូរសព្ទពីលេខទូរសព្ទផ្ទះទៅកាន់លេខ ‘13’ ពីកន្លែងណាមួយនៅក្នុងប្រទេសអូស្ត្រាលីត្រូវបានគិតថ្លៃ តាមអត្រាថេរ។ អត្រានោះអាចប្រែប្រួលពីតម្លៃនៃការហៅទូរសព្ទនៅក្នុងតំបន់ ហើយក៏អាចប្រែប្រួលរវាងអ្នកផ្ដល់សេវាទូរសព្ទនានា ផងដែរ។ ការហៅទូរសព្ទទៅលេខ ‘1800’ ពីលេខទូរសព្ទផ្ទះរបស់អ្នកគឺឥតគិតថ្លៃ។ ការហៅទូរសព្ទពីទូរសព្ទសាធារណៈ និងទូរសព្ទដៃអាចត្រូវបានគិតម៉ោង ហើយអាចគិតថ្លៃតាមអត្រាកាន់តែខ្ពស់។

## ការប្រកាសមិនទទួលខុសត្រូវ

ព័ត៌មានដែលមាននៅក្នុងការបោះពុម្ពផ្សាយនេះមានគោលបំណងតែជាការណែនាំចំពោះការបង់ប្រាក់ និងសេវាកម្មនានាប៉ុណ្ណោះ។ ជាការទទួលខុសត្រូវរបស់អ្នកដើម្បីសម្រេចចិត្ត ប្រសិនបើអ្នកប្រាថ្នាចង់ដាក់ពាក្យសុំការបង់ប្រាក់ និងដើម្បី ធ្វើការដាក់ពាក្យសុំទាក់ទងនឹងកាលៈទេសៈពិសេសរបស់អ្នក។

# Support for new parents on leave from work

Help if you are a parent taking time off work to care for a newborn or recently adopted child.

## Parental Leave Pay

This payment helps parents take time off work to be the primary carer of a new child.

If eligible, you can get up to 18 weeks pay at the rate of the National Minimum Wage. Parental Leave Pay is taxable. We also count it in the income test if you get an income support payment, such as Parenting Payment. This means if you get Parental Leave Pay your income support payment may reduce or stop.

## Who can get it?

You may get Parental Leave Pay if you:

- are the primary carer of a newborn or newly adopted child
- earned less than $150,000 in the last financial year
- have worked 10 of the 13 months before the birth or adoption of your child
- meet residence rules.

To get the full 18 weeks of Parental Leave Pay you must be on leave or not working during your Paid Parental Leave period.

If you cannot get Parental Leave Pay, you may get Newborn Upfront Payment and Newborn Supplement. You may get this if you are getting Family Tax Benefit Part A.

## When you can get it

When you claim you will choose a start date. Your start date cannot be before the date of birth or adoption.

You can nominate the date of birth or adoption as the start date. To do this, you need to do both of the following within 4 weeks after the birth or adoption:

- submit your claim
- provide proof of birth or adoption.

If you do not, your start date can only be from the date you submitted your claim.

You can also nominate a later start date.

To get the full 18 weeks of Parental Leave Pay, you need to claim and nominate a start date. You need to do this no more than:

- 34 weeks after the birth or adoption of a child, if this is before 1 July 2020
- 40 weeks after the birth or adoption of a child, if this is on or after 1 July 2020.

You will get your first payment after your nominated start date.

## How you will get Parental Leave Pay

Parental Leave Pay is paid for up to 18 weeks. This is 90 payable days.

If your child’s birth or adoption is before 1 July 2020, your Paid Parental Leave period will be a single continuous block of up to 18 weeks.

If your child’s birth or adoption is on or after 1 July 2020, your Parental Leave Pay will include both:

- a continuous Paid Parental Leave period of up to 12 weeks which is 60 payable days
- 30 Flexible Paid Parental Leave days.

If your child's birth or adoption is on or after 1 July 2020, you can use your Flexible Paid Parental Leave days in several ways. You can:

- connect them to your Paid Parental Leave period
- access them later at a time that suits you
- give them to another person such as your partner, to use on days that they have care of the child.

You can get Flexible Paid Parental Leave on days that you:

- are caring for your child
- are on leave or not working
- meet residence rules.

Your employer or we will pay your Parental Leave Pay, depending on your circumstances.

If your employer pays you, you will get your pay in your usual pay cycle. We will work this out with your employer.

If you do not get your Parental Leave Pay from your employer, or if you are self-employed, we will pay you directly every fortnight.

We can pay them within 104 weeks of your child’s birth or adoption. We will pay any Flexible Paid Parental Leave days that you have not connected to your Paid Parental Leave period.

## Dad and Partner Pay

Dad and Partner Pay is a payment for up to 2 weeks. It helps fathers or partners take time off work to care for their new child.

If you are eligible, you can get up to 2 weeks pay at the rate of the National Minimum Wage. We will pay you directly into your nominated bank account in one payment. Dad and Partner Pay is taxable.

You can get Dad and Partner Pay any time within 52 weeks of your child’s birth or adoption.

## Who can get it?

You may be able to get Dad and Partner Pay if you are either the:

- biological father of the child
- partner of the birth mother
- adoptive parent or partner of an adoptive parent
- person caring for a child born of a surrogacy agreement.

You also need to meet all of the following:

- provide care for a newborn or newly adopted child
- earned less than $150,000 in the last financial year
- not be working or taking paid leave during your Dad and Partner Pay period
- meet the work test

- meet residence rules.

## Work test for Parental Leave Pay and Dad and Partner Pay

To get Parental Leave Pay or Dad and Partner Pay, you need to meet the work test. You must have worked for at least 330 hours, around 1 day a week. You need to have worked these hours in 10 of the 13 months either:

- before the birth or adoption of your child, for Parental Leave Pay
- before the date your Dad and Partner Pay period starts.

If your child's birth or adoption is before 1 January 2020, you cannot have more than an 8 week gap between each work day.

If your child's birth or adoption is on or after 1 January 2020, you cannot have more than a 12 week gap between each work day.

Some exceptions apply for premature birth and pregnancy related illness and complications.

For Parental Leave Pay there is a Dangerous Jobs provision. This is if your child's birth or adoption is on or after 1 January 2020. It will apply if you had to stop work because there was a risk to your pregnancy. You will still need to meet the work test to get Parental Leave Pay.

## How to claim Parental Leave Pay or Dad and Partner Pay

4. Get a Customer Reference Number (CRN)

You will need to establish your identity to get a CRN. If you already have one and have confirmed your identity, use it to link your Centrelink online account to your myGov account.

5. Lodge your claim by using your Centrelink online account through myGov

You can do this up to 3 months before your child's expected date of birth or adoption.

6. Give us proof of your child's birth or adoption

You will need to submit proof of your child's birth or adoption within 4 weeks of them coming into your care. If you do not, you cannot be paid from their date of birth or adoption.

After your child's birth you will get a Newborn Child Declaration form from your hospital or midwife. You can upload this form online.

You will also need to register the birth with the Births, Deaths and Marriages Registry in your state or territory.

## Workplace leave entitlements

Parental Leave Pay and Dad and Partner Pay will not change any of your workplace leave entitlements.

To arrange leave, you will need to talk to your employer. You should try to do this at least 10 weeks before you intend to take leave.

You may have an entitlement to unpaid parental leave. This is if you have worked continuously for your employer for 12 months or more.

To learn more about your workplace leave entitlements in English:

- go to **fairwork.gov.au**
- call the Fair Work Ombudsman on **131 394**
- go to **supportingworkingparents.humanrights.gov.au**

## For more information

- Call your regular payment line and let us know you need an interpreter. We will arrange one for free. For a list of our phone numbers, go to **servicesaustralia.gov.au/phoneus**
- Call **131 202** to speak with us in your language about Centrelink payments and services.
- Call the Translating and Interpreting Service (TIS National) on **131 450** to speak with us in your language about Medicare and Child Support payments and services.
- Go to **servicesaustralia.gov.au/yourlanguage** where you can read, listen to or watch information in your language.
- Go to **servicesaustralia.gov.au/parentalleavepay** or **servicesaustralia.gov.au/dadandpartnerpay** for more information in English.
- Visit a service centre.

**Note**: calls from your home phone to ‘13’ numbers from anywhere in Australia are charged at a fixed rate. That rate may vary from the price of a local call and may also vary between telephone service providers. Calls to ‘1800’ numbers from your home phone are free. Calls from public and mobile phones may be timed and charged at a higher rate.

## Disclaimer

The information contained in this publication is intended only as a guide to payments and services. It is your responsibility to decide if you wish to apply for a payment and to make an application with regard to your particular circumstances.